00355692

ឯកសារ/N: D 180/2

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification) 26 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស៊ើ

ដាក់ជូន: ការិយាល័យសហចៅក្រមស៊ើបអង្កេត

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ និង លោក នួន ជា

កាលបរិច្ឆេទដាក់ឯកសារ: ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៩

ភាសាដើម: ភាសាអង់គ្លេស

សាធារណៈ
PUBLIC

ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់ 26/01/2010

ចំណាត់ថ្នាក់ឯកសារដោយ កសចស:

ប្រភេទចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 07 / 2009
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

---

## ចម្លើយតបរួមរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងវិក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ

---

**ដាក់ឯកសារដោយ៖**

**សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLI, QC

**សហមេធាវីរបស់លោក នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**ចែកចាយជូន៖**

**សហចៅក្រមស៊ើបអង្កេត**

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

**សហព្រះរាជអាជ្ញា:**

អ្នកស្រី ជា លាង

លោក Robert PETIT

**មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាងទាំងអស់**

00355693

ឯកសារ: D180/2

# I. សេចក្តីផ្តើម និង ការទាមទារ

1. នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៩ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ "សំណើរបស់សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ ("សំណើ")[1] ។

2. មេធាវីការពាររបស់ អៀង ធីរិទ្ធ និង នួន ជា សូមច្រានចោលសំណើនេះ និង "សូមដាក់ចម្លើយតបរួមទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ" ។

# III. អំណះអំណាង I-ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចស្នើសុំបន្ថែមបទល្មើសថ្មីបានឡើយ

## ៣.១ បទដ្ឋានច្បាប់ពាក់ព័ន្ធ

3. វិធាន ៥៥ នៃវិធានផ្ទៃក្នុងដែលនៅពេលនេះនៅតែពាក់ព័ន្ធ ចែងថា:

(២) សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតតែអង្គហេតុណាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។

(៣) ក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើមានលេចចេញអង្គហេតុថ្មី សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មានដល់សហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុនោះជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានដែលមានស្រាប់។ កាលណាអង្គហេតុថ្មីនេះត្រូវបានបញ្ជូនទៅឱ្យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបអង្កេតអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា។

(៥) ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបសួរអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬ ភស្តុតាងដោះបន្ទុកក៏ដោយ។ [...] ។

[1] សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៩ ឯកសារលេខ D180 ។ មេធាវីការពារក្តីត្រូវបានជូនដំណឹងពីឯកសារនេះនៅថ្ងៃទី៨ ខែកក្កដា ២០០៩។

4. វិធាន ៤៩ នៃវិធានផ្ទៃក្នុងចែងថា "ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងឡាយដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ អាចធ្វើឡើងបានតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ទោះបីជាការសម្រេចចិត្តដោយឯកឯង ឬ ដោយផ្អែកតាមពាក្យបណ្តឹងក៏ដោយ។

## ៤.២ សេចក្តីសន្និដ្ឋាន

5. អង្គហេតុរបស់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាមូលដ្ឋានសម្រាប់ការស៊ើបសួររបស់ កសចស ហើយ ភាគីអាចស្នើសុំឲ្យកសចសបំពេញកិច្ចស៊ើបសួរលើអង្គហេតុ តាមរយៈសំណើសុំបំពេញកិច្ចស៊ើបសួរ។ អំណាចស៊ើបសួររបស់ កសចស ត្រូវបានដាក់កម្រិតចំពោះតែអង្គហេតុណាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែប៉ុណ្ណោះ ដូចមានចែងនៅក្នុងវិធាន ៥៥ នៃវិធានផ្ទៃក្នុង។ វិធាន ៤៩ ចែងថា មានតែសហព្រះរាជអាជ្ញាទេដែលកំណត់អំពីបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់មកលើជនត្រូវចោទ ហើយការចោទប្រកាន់បែបនេះ "អាចត្រូវបានផ្តួចផ្តើមគំនិតដោយសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ"។ អាស្រ័យហេតុនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចស្នើសុំ កសចស ដើម្បីស៊ើបសួរអង្គហេតុណាដែលមិនបានបង្កើតជាបទឧក្រិដ្ឋនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរឡើយ។

6. ចំពោះបញ្ហានោះ ប្រសិនបើ កសចស ឬ ដើមបណ្តឹងរដ្ឋប្បវេណីមានបំណងថា ជនត្រូវចោទត្រូវតែចោទប្រកាន់ពីបទឧក្រិដ្ឋជាច្រើនទៀត លើសពីបទឧក្រិដ្ឋបច្ចុប្បន្នដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ វិធីដ៏សមរម្យបំផុតនោះគឺត្រូវជូនដំណឹងដល់កសពអំពីសំណើបែបនេះ ដើម្បីឲ្យការិយាល័យនេះសម្រេចថាតើដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមអនុលោមតាមវិធាន ៥៥(៣) ឬ មិនដាក់ ។

7. លុះត្រាតែ និងរហូតដល់ កសព ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កសចស ពុំមានអំណាចដើម្បីស៊ើបអង្កេតបទឧក្រិដ្ឋបន្ថែមដែលស្នើឡើងដោយសំណើនេះឡើយ ។

## IV. អំណះអំណាង II- ពុំមានយុត្តាធិការដើម្បីចោទប្រកាន់ពីបទឧក្រិដ្ឋនៃការឃាត់ខ្លួនដោយបំពាន

## ៤.១ បទដ្ឋានច្បាប់ពាក់ព័ន្ធ

00355695



8. មាត្រា ៥ នៃច្បាប់បង្កើត អវតក ចែងថា:[2]

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាល គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ជាដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយ ដូចជា:

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើឲ្យទៅជាទាសករ
- ការនិរទេស
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា
- អំពើអមនុស្សធម៌ផ្សេងៗទៀត

9. មាត្រា ១ នៃច្បាប់បង្កើត អវតក ចែងថា:

ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ។

និងមាត្រា ១ នៃកិច្ចព្រមព្រៀងចែងថា:[3]

---

[2] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“**ច្បាប់បង្កើតអវតក**”)៕

[3] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“**កិច្ចព្រមព្រៀង**”) អនុម័តនៅថ្ងៃទី៦ មិថុនា ២០០៣។

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និង ទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩។ ក្នុងចំណោមប្រការផ្សេងទៀត កិច្ចព្រមព្រៀងនេះផ្តល់មូលដ្ឋាន គតិយុត្តិយុត្ត និងបែបបទសម្រាប់កិច្ចសហប្រតិបត្តិការនេះ។

10. មាត្រា ២(១) នៃកិច្ចព្រមព្រៀងចែងថា:

កិច្ចព្រមព្រៀងនេះទទួលស្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរឿងក្តី ដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ [...] ។

11. មាត្រា ១២(១) នៃកិច្ចព្រមព្រៀងដែលនៅតែពាក់ព័ន្ធ ចែងថា:

នីតិវិធីត្រូវស្របជាមួយច្បាប់កម្ពុជា [...] ។

12. មាត្រា ១៣ នៃកិច្ចព្រមព្រៀងដែលនៅតែពាក់ព័ន្ធ ចែងថា:

សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ [...] ។

13. មាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមដែលនៅតែពាក់ព័ន្ធ ចែងថា:

សម្រាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" មានន័យថាជាអំពើណាមួយខាងក្រោមដែលត្រូវបានប្រព្រឹត្ត ជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយដឹងអំពីការវាយប្រហារបែបនេះ៖

[...]

(១) ការធ្វើអោយបាត់ខ្លួនមនុស្សដោយបង្ខំ

[...]

14. អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងនៅក្នុងមាត្រា ១៥ ថា:

គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើស ស្របតាមច្បាប់ជាតិ ឬអន្តរជាតិ ក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងពេលប្រព្រឹត្តបទល្មើសឡើយ ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន នោះជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលនេះ។

## ៤.២ សេចក្តីសន្និដ្ឋាន

### <u>៤.២.១ បទឧក្រិដ្ឋដែលស្នើសុំឱ្យស៊ើបសួរស្ថិតនៅក្រៅយុត្តាធិការរបស់អ.វ.ត.ក</u>

15. មេធាវីការពារសូមដាក់ជូនថាឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំមិនស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ទេ ហេតុដូច្នេះ សំណើនេះត្រូវតែបដិសេធចោល។

16. សំណើនេះបានធ្វើការអះអាងដូចខាងក្រោម:

> សរុបសេចកក្តីមក ការបាត់ខ្លួនមនុស្សដោយបង្ខំបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅពេលបទល្មើសនេះត្រូវបានគេប្រព្រឹត្តក្នុងលក្ខណ:ជាទូទៅ ឬស៊ីចង្វាក់គ្នា ហើយការហាមឃាត់មិនអោយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បង្កើតបានជាវិធានដែលត្រូវតែអនុវត្ត *(jus cogens)* ដែលនាំឱ្យមានកាតព្វកិច្ចសម្រាប់ជនគ្រប់រូប *(Erga Omnes)* ក្នុងការកាត់សេចក្តី។ អាស្រ័យហេតុនេះ តាមរយ:ការិយាល័យចៅក្រមស៊ើបអង្កេត តុលាការនេះមានភារកិច្ចក្រោមច្បាប់អន្តរជាតិ ដើម្បីស៊ើបអង្កេតនូវការកើតឡើងនៃឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ ក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ[4]។

17. ដើមបណ្តឹងរដ្ឋប្បវេណីភ្លេចនៅទីនេះថា មានភាពខុសគ្នារវាងច្បាប់នៅថ្ងៃនេះ និងច្បាប់នៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់តុលាការនេះ ឧទាហរណ៍ឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។ ខណ:ផ្តល់អំណះអំណាងថា បទឧក្រិដ្ឋថ្ងៃនេះស្ថិតនៅក្រោមក្រុមនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬគ្រាន់តែជា វិធានដែលត្រូវតែអនុវត្ត (jus cogens) សំណើនេះមិនបានផ្តល់ទឡ្ហីករណ៍ទាក់ទងនឹងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ហើយទឡ្ហីករណ៍បែបនេះក៏មិនអាចបង្ហាញដែរ។

18. គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យមានការចោទប្រកាន់ពីបទឧក្រិដ្ឋមួយ គឺត្រូវតែផ្អែកលើបទដ្ឋានច្បាប់ដែល(១)មាននៅពេលប្រព្រឹត្តបទល្មើស (*Nullum crimen sine lege:* គោលការណ៍

---

[4] សំណើ កថាខណ្ឌ ៧ ។

00355698



គ្មានទោសបើគ្មានច្បាប់ចែង), (២) ដែលអាចយល់ដោយបុគ្គលដែលស្វែងរកដំណោះស្រាយពីច្បាប់នោះ និង(៣) ប្បញ្ញត្តិយ៉ាងច្បាស់ដែលអាចបង្កលទ្ធភាពឱ្យមានការចោទប្រកាន់ និងដាក់ទណ្ឌកម្មដែលអាចប្រមើលឃើញបាន (វិធានពិតប្រាកដ-Lex certa)[5]។ មាត្រា ១៥(១) នៃអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលអាចអនុវត្តដោយផ្ទាល់ចំពោះដំណើរការនីតិវិធីរបស់ អ.វ.ត.ក តាមរយៈមាត្រា ១៣ នៃកិច្ចព្រមព្រៀង ចែងថាៈ

> គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬ ការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលប្រព្រឹត្តបទល្មើសនោះឡើយ។

19. ដើម្បីអាចឱ្យអនុវត្តបាននៅចំពោះ អ.វ.ត.ក បទឧក្រិដ្ឋ[6]ៈ

ក. ត្រូវតែមានចែងនៅក្នុងច្បាប់បង្កើត អ.វ.ត.ក ។

ខ. ត្រូវតែបានចាត់ជាបទល្មើសព្រហ្មទណ្ឌដោយក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ។

គ. បង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់តុលាការនេះ ។

ឃ. ត្រូវតែបានចាត់ជាបទល្មើសព្រហ្មទណ្ឌដោយអនុសញ្ញាអន្តរជាតិមួយដែលអាចអនុវត្តបានដោយផ្ទាល់ចំពោះដំណើរការនីតិវិធីរបស់ អ.វ.ត.ក

<u>៤.២.២ បទឧក្រិដ្ឋនេះមិនមានចែងនៅក្នុងច្បាប់បង្កើត អ.វ.ត.ក</u>

*៤.២.២.១ ឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំមិនបានចែងនៅក្នុងច្បាប់បង្កើត អ.វ.ត.ក នោះទេ*

20. ឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំមិនបានបញ្ចូលនៅក្នុងច្បាប់បង្កើត អ.វ.ត.ក ហើយក៏មិនបានរាយឈ្មោះថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងមាត្រា ៥ ឬ នៅផ្នែកដទៃទៀតនៃច្បាប់នេះដែរ។ សម្រាប់មូលហេតុនេះ សំណើនេះស្ថិតនៅក្រៅយុត្តាធិការរបស់ អវតក ហើយត្រូវតែបដិសេធចោល។

*៤.២.២.២ ច្បាប់បង្កើត អវតក មានអាទិភាពលើកិច្ចព្រៀមព្រៀង*

---

[5] W.N. Ferdinandusse, ការអនុវត្តនីតិព្រហ្មទណ្ឌអន្តរជាតិដោយផ្ទាល់នៅក្នុងតុលាការជាតិ (២០០៦) ទំព័រ ២២៣ ។

[6] សូមមើលមាត្រា ១ នៃច្បាប់បង្កើត អ.វ.ត.ក និង មាត្រា ១ នៃកិច្ចព្រមព្រៀង ។

21. សំណើសុំបំពេញកិច្ចស៊ើបសួរនេះអះអាងថា កិច្ចព្រមព្រៀងមានអាទិភាពលើច្បាប់បង្កើត អវតក[7] សម្រាប់ការអះអាងនោះ អំណះអំណាងគឺថា កិច្ចព្រមព្រៀងមានអាយុចំណាស់ជាង ហេតុដូច្នេះ សាកសមទទួលសិទ្ធិបុរិមាលើច្បាប់បង្កើត អវតក ដែលត្រូវបានពង្រាងនៅពេលក្រោយ។ សំណើនេះអះអាងពីការពឹងផ្អែកលើ "គោលការណ៍ច្បាប់កើតមុន (*Lex prior*)"[8]។ គួរឲ្យចាប់អារម្មណ៍ដែរនោះ ប្រភពដែលប្រើនៅក្នុងសំណើបានបញ្ជាក់យ៉ាងច្បាស់នូវគោលការណ៍ដែលមានអាទិភាព គឺមិនមានគោលការណ៍ *Lex prior* នោះទេ តែជាគោលការណ៍ច្បាប់កើតក្រោយ (*lex posterior derogat legi priori)* ទៅវិញទេ ដែលមានន័យផ្ទុយស្រឡះពីអំណះអំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសច្បាប់កើតក្រោយមានអធិកភាពលើច្បាប់កើតមុន[9]។ ម្យ៉ាងវិញទៀត ខណៈមានវិសោធនកម្មជាច្រើនត្រូវបានអនុម័តទៅលើច្បាប់បង្កើត អវតក នៅឆ្នាំ២០០៤ ក៏ពុំមានការផ្លាស់ប្តូរបទប្បញ្ញត្តិស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ។ អ្វីដែលមេធាវីការពារក្តីដឹង គឺពុំមានការលើកឡើងនៅដំណាក់កាលនោះ ពីការដាក់បញ្ចូលឧក្រិដ្ឋកម្មនៃការបាត់ខ្លួនទេ។

---

[7] សំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១១-១៤ បានគូសបញ្ជាក់ថាកិច្ចព្រមព្រៀងមានអធិកភាពលើច្បាប់បង្កើត អវតក ទាក់ទងនឹងអវត្តមាននៃធាតុផ្សំនៅក្នុងមាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ដែលធាតុផ្សំរបស់វាមានវត្តមាននៅក្នុងច្បាប់បង្កើត អវតក។ អំណះអំណាងដូចគ្នាដែលបានបញ្ជាក់នៅទីនេះទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ ហើយក៏បានលើកឡើងពីលិខិតុបករណ៍ច្បាប់មួយណា ដូចជាច្បាប់បង្កើត អវតក ឬ កិច្ចព្រមព្រៀង អាចអនុវត្តបានចំពោះការពិភាក្សាលើធាតុផ្សំ។ បន្ថែមពីលើនេះ ការដែលថាមាត្រា ៣ នៃច្បាប់លក្ខន្តិកៈរបស់ ICTY តម្រូវនូវធាតុផ្សំបែបនេះ មានន័យថា អវត្តមាននៃធាតុផ្សំបែបនេះ មិនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអម្លុងឆ្នាំ ១៩៧៥-១៩៧៩ នោះទេ។ សូមមើល K. Khan & R. Dixon, *Archbold* តុលាការព្រហ្មទណ្ឌអន្តរជាតិ(២០០៥) ទំព័រ ៦៣០ ដែលលើកឡើងថា ប្រតិភូរបស់រដ្ឋខ្វែងយោបល់ថាតើត្រូវបញ្ចូល ឬ មិនបញ្ចូលធាតុផ្សំនៃមាត្រា ៧ នៃច្បាប់លក្ខន្តិកៈរបស់ ICTY ។ ការថ្លែងនៅកថាខណ្ឌ ១៧ នៃសំណើដែលថា ធាតុផ្សំនឹងធ្វើឲ្យបរាជ័យលើគោលបំណងរបស់កិច្ចព្រមព្រៀង ក៏ពុំមានទម្ងន់ដែរ គឺមិនត្រឹម និងមិនពាក់ព័ន្ធ។ គោលបំណងរបស់កិច្ចព្រមព្រៀងមិនបានគ្របដណ្តប់លើធាតុផ្សំដែរ ហើយទឡ្ហីករណ៍បែបនេះក៏មិនត្រូវបានលើកឡើងដែរ ហើយសំខាន់ជាងនេះទៅទៀត ការអនុវត្តច្បាប់បង្កើតអវតក មិនត្រូវពឹងផ្អែកលើគោលបំណងនៃកិច្ចព្រមព្រៀងដែរ។ ក្នុងការបកស្រាយអំពីខ្វះខាតនៃធាតុផ្សំនេះ គោលការណ៍វិមតិសង្ស័យ (*in dubio pro reo*) ត្រូវតែបានពិចារណា។ សូមមើលខាងក្រោម ។

[8] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១១ ។

[9] មហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥៨ ILC 58th Session, A/CN.4/L.682, Martti Koskenniemi, "ការបែកបាក់នៃច្បាប់អន្តរជាតិ: ភាពលំបាកកើតចេញពីការចែកមែកធាង និង ការរីកដុះដាលនៃច្បាប់អន្តជាតិ (Diversification and Expansion of International Law) ថ្ងៃទី ៤ ខែ មេសា ២០០៦ កថាខណ្ឌ ២២៥ និង ២៤៣។ សូមមើលផងដែរ Malcolm Shaw "នីតិសាធារណៈអន្តរជាតិ (២០០៦) ទំព័រ ១១៦ ។

អាស្រ័យហេតុនេះ អំណះអំណាងនេះមិនអាចធានាថា កិច្ចព្រមព្រៀងមានអាទិភាពជាងបានទេ បើឈរលើមូលដ្ឋាននេះ ហើយប្រសិនបើ កសចស ពិចារណាលើអំណះអំណាងនៃភាពអាចអនុវត្តបាននៃ *Lex prior* ឲ្យបានស៊ីជំរៅ នោះគេអាចនិយាយបានថាច្បាប់បង្កើត អវតក ដំបូងត្រូវបានអនុម័ត រួចហើយកាលពីឆ្នាំ២០០១ មុនការអនុម័តកិច្ចព្រមព្រៀងទៅទៀត។ ហេតុដូច្នេះ បទប្បញ្ញត្តិនៃច្បាប់បង្កើត អវតក ដំបូង ត្រូវតែមានអាទិភាព ហើយមិនបានបញ្ចូលបទប្បញ្ញត្តិស្តីពីឧក្រិដ្ឋកម្ម នៃការបាត់ខ្លួនទេ។ ដូចគ្នានេះដែរ ការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថា[10] ច្បាប់បង្កើត អវតក មិនស្របជាមួយគោលបំណងរបស់កិច្ចព្រមព្រៀង គឺពុំមានទម្ងន់ ហើយក៏មិនអាចអះអាងថាពិតដែរ ដោយសារការបញ្ចូលឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំមិនអាចត្រូវបានពិចារណាថាបង្កើតបាន ជាផ្នែកនៃគោលបំណងរបស់កិច្ចព្រមព្រៀង ហើយម្យ៉ាងវិញទៀត ការអនុវត្តច្បាប់បង្កើត អវតក មិនពឹងផ្អែកលើគោលបំណងរបស់កិច្ចព្រមព្រៀងដែរ ។

22. ដោយសារតែ កសចស ខ្លួនឯងបានពិចារណាយ៉ាងច្បាស់នៅក្នុង"ដីកាសម្រេចលើសំណើសុំបំពេញស៊ើបសួរ" ថា ខ្លួនទទួលបានអំណាចពីច្បាប់បង្កើត អវតក[11]។ នៅក្នុងការសម្រេចអំពីដែនកំណត់អំណាចរបស់ខ្លួននៅក្នុងដីកាសម្រេចនេះ កសចស យោងយ៉ាងច្រើនទៅលើច្បាប់បង្កើត អវតក ហើយមិនបានយោងទៅលើកិច្ចព្រមព្រៀងទេ។ ចំនុចនេះក៏បានបញ្ជាក់ថា ច្បាប់បង្កើត អវតក មានអាទិភាពលើកិច្ចព្រមព្រៀង។

23. បន្ថែមពីលើនេះ មេធាវីការពារសូមសន្និដ្ឋានថា "នៅពេលមានការទទួលស្គាល់ច្បាប់ព្រហ្មទណ្ឌជានិច្ចជាកាល ច្បាប់ដែលផ្តល់អត្ថប្រយោជន៍ច្រើនបំផុតដល់ជនជាប់ចោទ ត្រូវតែអនុវត្ត"[12] អនុលោមតាមគោលការណ៍វិមតិសង្ស័យ (*in dubio pro reo*) ឲ្យតែច្បាប់ ឬវិធាននោះ អាចត្រូវបានគេបកស្រាយយ៉ាងត្រឹមត្រូវ តាមវិធីសាស្ត្រពីរ ឬបីបែប នោះការបកស្រាយដែលផ្តល់អត្ថ

[10] សំណើ កថាខណ្ឌ ១២ អក្សរក្នុងលេខយោងទី ៣៤ ។

[11] ដីកាសម្រេចរបស់ កសចស លើសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣ ខែ មេសា ២០០៩ ឯកសារលេខ . D158/5, កថាខណ្ឌ ៨។

[12] របាយការណ៍របស់ ILC នៅមហាសន្និបាតលើកទី២៨ ឯកសារ No. A/31/10 (1976) ទំព័រ ៨៩ ។

ប្រយោជន៍ដល់ជនជាប់ចោទត្រូវតែជ្រើសរើស[13]។ គោលការណ៍នេះក៏តម្រូវឲ្យមានការអនុវត្តនូវច្បាប់បង្កើត អវតក ជាងកិច្ចព្រមព្រៀងដែរ។

24. បន្ថែមពីលើនេះ គោលការណ៍ច្បាប់ពិសេស (*lex specialis*) តម្រូវថាច្បាប់ពិសេសមានអធិកភាពលើច្បាប់ទូទៅ *(lex general)*[14]។ ដូចបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯង "ច្បាប់បង្កើត អវតក ត្រូវបានរៀបចំឡើងដើម្បីអនុវត្តបទបញ្ញត្តិនានាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង"[15]។ ការអនុវត្តគោលការណ៍ *lex general* មានន័យថាច្បាប់បង្កើត អវតក មានអាទិភាពលើការអនុវត្តកិច្ចព្រមព្រៀង។

25. ជាចុងក្រោយ កិច្ចព្រមព្រៀងខ្លួនឯងចែងថា ច្បាប់បង្កើត អវតក មានអាទិភាពលើកិច្ចព្រមព្រៀង មាត្រា ២(១) ចែងថា:

> កិច្ចព្រមព្រៀងនេះទទួលស្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរឿងក្តី ដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ [...] ។

26. ហើយមាត្រា ១២(១) នៃកិច្ចព្រមព្រៀងចែងថា "នីតិវិធីត្រូវស្របជាមួយច្បាប់កម្ពុជា ឧទាហរណ៍ ស្របជាមួយច្បាប់បង្កើត អវតក ។

*៤.២.២.៣ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ យោងតែច្បាប់បង្កើត អវតក ប៉ុណ្ណោះ*

---

[13] សូមមើល See K. Khan & R. Dixon, *Archbold* តុលាការព្រហ្មទណ្ឌអន្តរជាតិ(២០០៥) ទំព័រ១៦៥។ ឧទាហរណ៍ គោលការណ៍នេះ ត្រូវបានទទួលស្គាល់ដោយរឿងក្តី អយ្យការតទល់ជាមួយ *Akayesu* សាលក្រមចុះថ្ងៃទី២ ខែកញ្ញា ១៩៩៨ កថាខណ្ឌ ៣១៩ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងរបស់ ICTR បានសម្រេចថា "ដោយសារតែគោលការណ៍ទូទៅរបស់ច្បាប់ចែងថា នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ការបកស្រាយដែលផ្តល់អត្ថប្រយោជន៍ដល់ជនជាប់ចោទ ត្រូវតែជ្រើសរើស"។

[14] មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ILC 58th Session, A/CN.4/L.682, Martti Koskenniemi, "ការបែកបាក់នៃច្បាប់អន្តរជាតិ: ភាពលំបាកកើតចេញពីការចែកមែកធាង និង ការរីកដុះដាលនៃច្បាប់អន្តជាតិ (Diversification & Expansion of International Law) ថ្ងៃទី ៤ ខែ មេសា ២០០៦ កថាខណ្ឌ ៥៦។ សូមមើលផងដែរ Malcolm Shaw "នីតិសាធារណៈអន្តរជាតិ (២០០៦) ទំព័រ ១១៦ ។ K. Khan & R. Dixon, *Archbold* តុលាការព្រហ្មទណ្ឌអន្តរជាតិ (២០០៥) ទំព័រ ១៦៨។

[15] សំណើ កថាខណ្ឌ ១១។

27. ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ គូសបញ្ជាក់ថា ឯកសារនេះយោងតែច្បាប់បង្កើត អវតក និងមិនយោងកិច្ចព្រមព្រៀងទេ[16]។ សហព្រះរាជអាជ្ញា គឺជាអ្នកសម្រេចថាតើបទឧក្រិដ្ឋមួយណា ដែលត្រូវចោទប្រកាន់មកលើជនត្រូវចោទ[17]។ កិច្ចស៊ើបសួររបស់ កសចស ត្រូវបានដាក់កម្រិត ត្រឹមតែអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរតែប៉ុណ្ណោះ។ ហេតុដូច្នេះ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរក៏ត្រូវបានដាក់កម្រិតដោយឧក្រិដ្ឋកម្មដែលមាន ចែងនៅក្នុងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញផងដែរ។ ហេតុដូច្នេះ ការអនុវត្តឧក្រិដ្ឋកម្មដែលមិន មែនជាផ្នែកមួយនៃច្បាប់បង្កើត អវតក ត្រូវស្ថិតនៅក្រៅអំណាចរបស់ កសចស ។

<u>៤.២.៣ ឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំមិនមែនជាផ្នែកមួយនៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦</u>

28. ដើម្បីអាចចោទប្រកាន់ជនជាប់ចោទនៅចំពោះ អវតក ពីបទឧក្រិដ្ឋដែលមិនមែនជាផ្នែកមួយនៃ ច្បាប់បង្កើត អវតក ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន បទឧក្រិដ្ឋកម្មនេះត្រូវតែបញ្ចូលទៅក្នុង ក្រមព្រហ្មទណ្ឌកម្ពុជា ដែលអាចអនុវត្តបានក្នុងអំឡុងពេលយុត្តាធិការនៃពេលវេលារបស់អង្គជំនុំ ជម្រះវិសាមញ្ញ ដែលច្បាប់នោះគឺក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ ក្រមព្រហ្មទណ្ឌនេះមិនបានយោង ទៅលើបទឧក្រិដ្ឋបែបនេះ ហើយដើមបណ្ដឹងរដ្ឋវេណីក៏មិនបានចោទប្រកាន់ដែរ។

### ៤.២.៤ ការបាត់ខ្លួនដោយបង្ខំមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ៧៥-៧៩ នោះទេ

---

[16] ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ទំព័រ ១ ចែងថា:

"យើង, សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា:

- បានឃើញច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបាន ប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ។
- បានឃើញវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចូលជាធរមាននៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៧ ។
- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ០០២ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ នៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ។
- [...]"

[17] វិធាន ៥៩ នៃវិធានផ្ទៃក្នុង ។

29. សំណើសុំសំអាងទៅលើលក្ខន្តិកៈទីក្រុងរ៉ូមដើម្បីបញ្ជាក់ថា ការបាត់ខ្លួនដោយបង្ខំបង្កទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សំណើនេះលើកឡើងថា:

ជាលទ្ធផល គោលការណ៍ច្បាប់អន្តរជាតិបានចែងយ៉ាងច្បាស់ថា ការប្រព្រឹត្តជាទូទៅ និងជាប្រព័ន្ធនៃការបាត់ខ្លួនមនុស្សដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[18]។

30. ការបាត់ខ្លួនដោយបង្ខំមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ នៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់សាលាក្តីនេះ ហើយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក៏មិនបានជជែកតវ៉ាចំនុចនេះនៅក្នុងកថាខណ្ឌ ៨ នៃ សំណើរបស់ខ្លួនដែរ។ ក្នុងអំឡុងពីឆ្នាំ ១៩៧៥-១៩៧៩ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនបានរាប់បញ្ចូលការបាត់ខ្លួនដោយបង្ខំនោះទេ។

31. សំណើសុំនោះច្រឡំអង្គហេតុដែលថា កាលពីមុន ការបាត់ខ្លួនដោយបង្ខំត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយលក្ខខណ្ឌចាំបាច់នោះគឺ វាត្រូវតែជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ដើម្បីអាចអនុវត្តបាននៅចំពោះមុខអវតក។ ប្រភពទាំងឡាយដែលបានលើកឡើងនៅក្នុងអក្សរក្នុងលេខយោងទី ២៦ អាចបញ្ជាក់ថា ការបាត់ខ្លួនដោយបង្ខំត្រូវបានទទួលស្គាល់ថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែ ខកខានមិនបានលើកឡើងថា នេះជាផ្នែកមួយនៃច្បាប់ទំនៀនទម្លាប់អន្តរជាតិ ដែលសាស្ត្រាចារ្យ Cassese បដិសេធយ៉ាងច្បាស់លាស់[19] ហើយដែលចំនុចនេះគឺជាករណីក្នុងចន្លោះពីឆ្នាំ ១៩៧៥ - ១៩៧៩ រួចទៅហើយ។

32. សំណើសុំយោងទៅលើលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់អំណះអំណាងនេះ។ ប៉ុន្តែ មូលដ្ឋានសម្រាប់ អវតក គឺច្បាប់ស្តីពីការបង្កើត អវតក មិនមែនលក្ខន្តិកៈទីក្រុងរ៉ូមនោះទេ ហើយសំណើសុំនោះមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ថាហេតុអ្វីបានជា កសចស គួរតែសំអាងឯកសារច្បាប់របស់តុលាការផ្សេងជំនួសឲ្យច្បាប់បង្កើត អវតក ទៅវិញនោះ។ ប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនៅក្នុងមាត្រា ៧(១)(ឈ)[20] នៃលក្ខន្តិកៈទីក្រុងរ៉ូមក៏មិនឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះដែរ ដែលយ៉ាងហោចណាស់ក៏ក្នុងអំឡុងយុត្តាធិការ អវតក ដូចដែល

---

[18] សំណើសុំ កថាខណ្ឌទី ៥ ។

[19] Antonio Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (២០០៣) ទំព័រ ៨០ & ៩៤ ។

[20] អក្សរក្នុងលេខយោងទី ៩ នៃសំណើសុំបានសំអាងទាំងភាន់ច្រឡំទៅលើគ្រា ៧(១)(ជ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ។

Antonio Cassese បានបញ្ជាក់ ដោយគាត់ពន្យល់ថា មាត្រា ៧(១)(ឈ) "ការបាត់ខ្លួនមនុស្ស ដោយបង្ខំ" មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[21]។

33. ប្រភពទីពីរ ដែលគាំទ្រដល់ការចោទប្រកាន់របស់ខ្លួនថា ការបាត់ខ្លួនបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អវតក គឺជាសេចក្តីប្រកាសស្តីពីការការពារគ្រប់មនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ[22]។ នៅក្រោមច្បាប់អន្តរជាតិ សេចក្តីប្រកាសមិនមែនជាលិខិតុបករណ៍ចងកាតព្វកិច្ច ហើយមិនបង្កើតបានជាប្រភពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអាចពង្រីកការអនុវត្តលក្ខន្តិកៈទីក្រុងរ៉ូមមក អវតក នោះទេ។

34. ចំណែកនៅក្នុងលេខត្រង់អក្សរយោងចុងទំព័រទី ២៣ ដើមបណ្តឹងរដ្ឋប្បវេណីជជែកតវ៉ាថា "[បើទោះបីជា] ការទទួលស្គាល់ជាអន្តរជាតិនៃច្បាប់មនុស្សជាតិលេចឡើងនៅក្នុងអំឡុងសតវត្សទី ២០ ក៏ដោយ ក៏ការប្រមូលដាក់ជាច្បាប់តែមួយ បានកើតឡើងជាដំបូងនៅក្នុងធម្មនុញ្ញនៃតុលាការសឹកអន្តរជាតិ នូរ៉ឹមប៊ឺក [...]"។ លេខត្រង់អក្សរយោងចុងទំព័រទី ២៤ សំអាងទៅលើសាលក្រមនូរ៉ឹមប៊ឺក។ ទោះជាយ៉ាងណាក៏ដោយ ការបាត់ខ្លួនដោយបង្ខំមិនបានបង្កើតជាផ្នែកមួយនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចំពោះមុខតុលាការនូរ៉ឹមប៊ឺក ដែលបានបង្ហាញដោយរឿងក្តីរបស់អគ្គមេបញ្ជាការប្រចាំការនៅសមរភូមិជនជាតិអាល្លឺម៉ង់ឈ្មោះ Wilhelm Keitel ដែលពីរឿងក្តីនោះ គេអាចទាញបានថា នៅពេលនៃសវនាការនូរ៉ឹមប៊ឺក ការបាត់ខ្លួនដោយបង្ខំនៅមិនទាន់ក្លាយជាផ្នែកមួយនៃទស្សនៈរបស់ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឡើយទេ។ ផ្ទុយទៅវិញ Keitel ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្ម សង្គ្រាម[23]។

35. នៅក្នុងលេខត្រង់អក្សរយោងចុងទំព័រទី ២៤ សំណើសុំនោះច្រឡំទស្សនៈទាននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងសិទ្ធិមនុស្ស។ ក្នុងខណៈដែល ICCPR និងលិខិតុបករណ៍អន្តរជាតិដទៃទៀតអាចបានធានា ដល់សិទ្ធិរស់រៀនមានជីវិត និងសិទ្ធិមនុស្សពាក់ព័ន្ធដទៃទៀត ជាយូរមកហើយនោះ

---

21 Antonio Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (២០០៣) ទំព័រ ៨០ & ៩៤ ។

22 សំណើសុំ កថាខណ្ឌទី ១០ ។

23 សូមមើល គណៈកម្មាធិការសិទ្ធិមនុស្ស សម័យប្រជុំលើកទី ៥៨ ឯកសារ E/NC.4/2002/71 ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០២ កថាខណ្ឌទី ៦៥។

ចំនុចនេះមិនបានគម្រូថា ការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌអាចធ្វើឡើងដោយយោងទៅលើមូលដ្ឋាននៃលិខិតុបករណ៍ សិទ្ធិមនុស្សបែបនោះទេ។

### ៤.២.៥ នៅក្នុងអនុសញ្ញាអន្តរជាតិមិនមានការបាត់ខ្លួនដោយបង្ខំទេ

36. បន្ថែមលើនេះទៅទៀត សំណើសុំនោះសំអាងទៅលើអនុសញ្ញាអន្តរជាតិមួយដើម្បីបង្ហាញថា បទឧក្រិដ្ឋ នៃការបាត់ខ្លួនដោយបង្ខំបង្កើតបានជាផ្នែកមួយនៃកម្មវត្ថុយុត្តាធិការរបស់ អវតក[24]។ ពួកគេសំអាងទៅលើអនុសញ្ញាមួយ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ មានន័យថា រយៈពេលដ៏យូរក្រោយពីអង្គហេតុជាច្រើន ដែលធ្លាក់ទៅក្នុងយុត្តាធិការរបស់ អវតក ត្រូវបានប្រព្រឹត្តឡើង។ ការអនុវត្តច្បាប់ *ប្រតិសកម្ម*មិនត្រូវបានអនុញ្ញាតនោះឡើយ ហើយវាអាចឈានទៅដល់ការរំលោភគោលការណ៍ *គ្មានបទល្មើសទេ បើគ្មានច្បាប់ចែង (nullum crimen sine lege)*។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាមិនមែនជាភាគីនៃអនុសញ្ញានេះទេ ហើយអនុសញ្ញានេះសោតទៀត មិនទាន់ចូលជាធរមាននៅឡើយទេ[25]។

37. ប្រភពផ្សេងទៀតដែលសំណើសុំយោង ដើម្បីគាំទ្រដល់ទ្រឹស្តីរបស់ខ្លួនថា បទល្មើសជាក់លាក់នេះស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក គឺអនុសញ្ញាអន្តរអាមេរិកកាំងស្តីពីការបាត់ខ្លួនមនុស្សដោយបង្ខំ និងករណី *Velasquez Rodriguez* ពីតុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង[26]។ ក្រៅពីការដែលថា ចំនុចនេះមិនបង្ហាញថាមានវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលផ្តន្ទាទោសការបាត់ខ្លួនដោយបង្ខំនោះ ឯកសារទាំងនេះចុះកាលបរិច្ឆេទក្រោយឆ្នាំ ១៩៧៩ ហេតុដូច្នេះមិនគាំទ្រដល់ទឡ្ហីករណ៍ដែលថា ការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មមួយនៅក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អវតក។ អត្ថបទសរសេរដោយ Bakker[27] ពន្យល់ថាការរកឃើញនៃបទដ្ឋានទំនៀមទម្លាប់ស្តីពីការបាត់ខ្លួនដោយបង្ខំ ដោយចៅក្រមមួយចំនួននៅក្នុងតុលាការកំពូល

---

[24] សូមមើល សំណើសុំ, លេខត្រង់អក្សរយោងចុងទំព័រទី ១២ ដែលសំអាងទៅលើអនុសញ្ញាអន្តរជាតិដើម្បីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ដែលបានអនុម័តនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦។ ឯកសារ A/61/488 ។

[25] សូមមើល "អនុសញ្ញាអន្តរជាតិដើម្បីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ" មកត្រឹមថ្ងៃទី៨ កក្កដា ២០០៨។ URLaddress:http://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-16&chapter=4&lang=en.

[26] សំណើសុំ, កថាខណ្ឌ ៥, លេខត្រង់អក្សរយោងចុងទំព័រទី ១០ ។

[27] សំណើសុំ, លេខត្រង់អក្សរយោងចុងទំព័រទី ១០ ។

អាហ្សង់ទីន មិនមែនជាការផ្ទុះបញ្ចាំងឲ្យបានគ្រប់គ្រាន់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ គឺមានតែបទដ្ឋានដាច់ខាត (*jus cogens*) ប៉ុណ្ណោះ[28]។

## V. ទឡ្ហីករណ៍ III-ចេតនាចំពោះការមានលក្ខណៈសម្បត្តិឡើងវិញៈ មិនមាន "អំពើអមនុស្សធម៌ផ្សេងទៀត"

38. ជាចុងក្រោយ សំណើសុំនោះលើកឡើងថា "ការបាត់ខ្លួនដោយបង្ខំ" គួរស្ថិតនៅក្រោមប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងទៀត"។ ជាថ្មីម្តងទៀត ការទំទាស់តវ៉ាដែលបានលើកឡើងខាងលើ ពាក់ព័ន្ធទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ អនុវត្តដូចគ្នានៅទីនេះ÷ ការបាត់ខ្លួនមនុស្សដោយបង្ខំមិនមែនជាផ្នែកមួយនៃច្បាប់ស្តីពីការបង្កើត អវតក, មិនមែនជាបទល្មើសនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធនោះ, មិនមែនជាផ្នែកមួយនៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងមិនបានចែងនៅក្នុងអនុសញ្ញាមួយដែលអាចអនុវត្តមកលើដំណើរការនីតិវិធីទាំងនេះបានទេ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានសម្រេចថា ឧក្រិដ្ឋកម្មនៃការជម្លៀសមនុស្សដោយបង្ខំ អាចស្ថិតនៅក្រោមប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀត ដោយសារវាត្រូវបានចាត់ទុកជាបទល្មើស នៅពេលការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។ ហេតុដូច្នេះ វាមិនបានរំលោភគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង (nullum crimen sine lege)* នោះទេ[29]។

---

[28] C.A.E. Bakker, ករណី *Simon* ។ A Full Stop ចំពោះការលើកលែងទោសនៅក្នុងប្រទេសអាហ្សង់ទីន, JICJ 3 (2005), ទំព័រ ១១១០ ការយល់ឃើញរបស់ចៅក្រមមិនមែនជាច្បាប់នោះទេ ពីព្រោះវាឆ្លុះបញ្ចាំងពីយោបល់ផ្ទាល់ខ្លួន គឺមិនមែនជាទស្សនៈរបស់តុលាការនោះទេ សូមមើល ទំព័រ ១១០៧។ សូម្បីតែអ្នកនិពន្ធខ្លួនឯងផ្ទាល់ក៏មានការខ្វែងយោបល់គ្នាពីអត្ថិភាពនៃបទដ្ឋាន ដាច់ខាតក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្ម*ទាំងអស់*ប្រឆាំងមនុស្សជាតិ ដើម្បីបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារតែកង្វះការអនុវត្តរបស់រដ្ឋ។ សូមមើលទំព័រ ១១៤ និង ១១១៦។ នៅក្នុងការឆ្លើយតបទៅនឹងការលើកឡើងជាហេតុផលរបស់ចៅក្រម Maqueda ដែលត្រូវបានដើមបណ្តឹងរដ្ឋប្បវេណីយកមកសំអាងនោះ Bakker លើកឡើងថា "វាពិតជា ជំទាស់ច្រើនជាមួយវិធីសាស្ត្របូរាណ ទៅនឹងច្បាប់អន្តរជាតិ" សូមមើលទំព័រ ១១៤ ផងដែរ។ Bakker លើកឡើងថា សម្រាប់តុលាការប្រទេសអាហ្សង់ទីន ការអនុវត្តរបស់រដ្ឋមិនមែនជាកត្តាបែបសេចក្តីសម្រេចនៅក្នុងការស្វែងរកបទដ្ឋានដាច់ខាតនោះទេ សូមមើលទំព័រ ១១១៦ ។ Bakker ខ្លួនឯងបញ្ជាក់ថា អត្ថិភាពនៃការយល់ឃើញរបស់ចៅក្រម និងការអនុវត្តរបស់រដ្ឋក្នុងឆ្នាំ ១៩៧៨ ចំពោះឧក្រិដ្ឋកម្មនេះ អាចជជែកតវ៉ាបាន។ សូមមើលទំព័រ ១១១៦ - ១១១៧។ ភាគច្រើនបទដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះវិសាលភាពនេះ អាចត្រូវបានគេយកវិនិច្ឆ័យបាន។

[29] សូមមើល *រដ្ឋអាជ្ញា តទល់នឹង Stakic* សាលដីកាលើសំណុំរឿងលេខ IT-97-24-A, ចុះថ្ងៃទី២២ មីនា ២០០៦ កថាខណ្ឌ ៣១៧ ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា "អង្គជំនុំជម្រះសាលាឧទ្ធរណ៍កត់សម្គាល់ឃើញថា មាត្រា ២(ឆ)

ផ្ទុយទៅវិញ គេអាចសន្និដ្ឋានថា ប្រសិនបើអំពើជាក់លាក់មួយមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនៅពេលវេលាពាក់ព័ន្ធនោះទេ វាអាចមិនស្ថិតនៅក្រោមប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀតនោះដែរ។

39. នៅក្នុងរឿងក្តីប្រឆាំងនឹង Zoran Kupreskic[30] សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រកឃើញថា ការបាត់ខ្លួនដោយបង្ខំអាចស្ថិតនៅក្រោមប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀត។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "ព្រំដែននៃការបកស្រាយអំពើអមនុស្សធម៌ផ្សេងទៀត" អាចត្រូវបានកំណត់ជំនួសនៅក្នុងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស"។ សាលាដំបូងនោះលើកឡើងថា:

> ដោយការសំអាងទៅលើបទប្បញ្ញត្តិផ្សេងៗនៃអត្ថបទទាំងនេះ គេអាចកំណត់សិទ្ធិជាមូលដ្ឋានមួយចំនួនដែលជាប់ទាក់ទិននឹងមនុស្សជាតិ។ ការរំលោភសិទ្ធិប្រភេទនេះ អាចនាំឲ្យកើតបានជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលត្រូវផ្អែកទៅលើកាលៈទេសៈពាក់ព័ន្ធ[31] ។

នៅក្នុងការសន្និដ្ឋានថា ការបាត់ខ្លួនមនុស្សដោយបង្ខំ អាចស្ថិតនៅក្រោមប្រភេទសេសសល់នៃអំពើអមនុស្សធម៌ផ្សេងទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY សំអាងទៅលើសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៤៧/១៣៣ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៩២ និង អនុសញ្ញាអន្តរអាមេរិកកាំង ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៤ ដែលអត្ថបទទាំងពីរនេះចុះកាលបរិច្ឆេទក្រោយយុត្តាធិការពេលវេលារបស់តុលាការនេះ។ ហេតុដូច្នេះ លក្ខណៈវិនិច្ឆ័យនៃការ

---

នៃលក្ខន្តិកៈ មាត្រា ៤៩ និងមាត្រា ១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ៨៥(៤)(ក) នៃពិធីសារបន្ថែម I និងមាត្រា ១៨ នៃសេចក្តីព្រាងក្រម ILC ឆ្នាំ ១៩៩៦ ផ្តន្ទាទោសការជម្លៀសមនុស្សដោយបង្ខំ។ ហេតុដូច្នេះ សញ្ញាណនៃការជម្លៀសមនុស្សដោយបង្ខំត្រូវបានទទួលស្គាល់យ៉ាងច្បាស់ថា អំពើដែលត្រូវបានដាក់ឲ្យព្រហ្មទណ្ឌនៅពេលវេលាពាក់ព័ន្ធទៅនឹងរឿងក្តីនេះ ដែលក្នុងករណីវាមិនរំលោភគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង (nullum crimen sine lege)*។

[30] រដ្ឋអាជ្ញា តទល់នឹង *Zoran Kupreskic,* សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ , សំណុំរឿងលេខ IT-95-16-T, កថាខណ្ឌទី ៥៦៦។

[31] រដ្ឋអាជ្ញា តទល់នឹង *Zoran Kupreskic,* សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០, សំណុំរឿងលេខ IT-95-16-T, កថាខណ្ឌទី ៥៦៦។

យល់ដឹងជាមុន[32]មិនត្រូវបានបំពេញនោះទេ ហើយអាចរំលោភគោលការណ៍ជាក់លាក់ *(lex certa principle)* ដោយការផ្តន្ទាទោសជនត្រូវចោទពីបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំ[33]។

40. ក្នុងករណីណាក៏ដោយ ការពិតដែលថា ច្បាប់ស្តីពីការបង្កើត អវតក នៅក្នុងទម្រង់កែប្រែរបស់វាត្រូវបានព្រាងឡើង*ក្រោយ*លក្ខន្តិកៈទីក្រុងរ៉ូម ហើយប្រភេទនៃការបាត់ខ្លួនដោយបង្ខំមិនត្រូវបានដាក់បញ្ចូលនោះ ត្រូវការបកស្រាយថា ជាការដកចេញដោយចេតនា។ ជាពិសេស ដោយសារកិច្ចព្រមព្រៀងបច្ចុប្បន្ននេះយោងទៅលើលក្ខន្តិកៈរ៉ូម ហើយច្បាប់ស្តីពីការបង្កើត អវតក ដែលបានតាក់តែងឡើងក្រោយពេលនោះ មិនបានដាក់បញ្ចូលបទល្មើសនេះ នោះគួរប្រកាន់យកគោលការណ៍ច្បាប់នេះ។ បទប្បញ្ញត្តិក្រោយដែលដកចេញ ការបាត់ខ្លួនដោយបង្ខំត្រូវតែបានបកស្រាយថាជាការលុបចោលដោយចេតនា ដែលមិនគួរត្រូវបានពង្វាងតាមរយៈការដាក់បញ្ចូលទៅក្នុងប្រភេទសេសសល់នៃអំពើ អមនុស្សធម៌ផ្សេងទៀតនោះទេ។ គោលការណ៍ *expressio unis est exclusio alterius* ចែងថា ការដកចេញជាក់ស្តែងនូវប្រភេទទាំងឡាយ នៅក្នុងច្បាប់ស្តីពីការបង្កើត អវតក អាចត្រូវបានគេ បកស្រាយថា ជាការដកចេញពិតៗនូវប្រភេទនៃការបាត់ខ្លួនដោយបង្ខំ។ ការបកស្រាយនេះពង្រឹងបន្ថែម ទៀតតាមរយៈគោលការណ៍នៃវិមតិសង្ស័យ *(the principle of in dubio pro reo)* ដែលលើកឡើងថា ការបកស្រាយដែលជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវតែយកមកប្រើប្រាស់[34]។

---

[32] ប្រភពដែលដើមបណ្តឹងរដ្ឋប្បវេណីសំអាងនៅក្នុងអក្សរត្រង់លេខយោងទី២៥ នៃសំណើសុំរបស់ខ្លួន មិនផ្ទុះបញ្ចាំងពីឧក្រិដ្ឋកម្មនៃការបាត់ខ្លួនមនុស្សដោយបង្ខំនោះទេ។

[33] ក្នុងន័យនេះ ឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានសម្រេចនៅចំពោះមុខតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូននោះ គឺខុសគ្នាពីឧក្រិដ្ឋកម្មបាត់ខ្លួនដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ធាតុផ្សំមួយចំនួននៃឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដូចជា បទរំលោភសេពសន្ថវៈ ទាសករផ្លូវភេទ និងពលកម្មដោយបង្ខំ អាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកពីគ្នា។ បើដូច្នេះ សេចក្តីសម្រេចនោះមិនបានរំលោភគោលការណ៍ជាក់លាក់ (*the principle of lex certa*) នោះទេ។ សូមមើល M. Frulli, "ច្បាប់ព្រហ្មទណ្ឌអន្តរជាតិជឿនលឿនៈ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន ទទួលស្គាល់អាពាហ៍ពិពាហ៍ដោយបង្ខំថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [ថ្មី] មួយ", J.I.C.J. (2008), ទំព័រ ១០៤០។

[34] សូមមើល K. Khan និង R. Dixon, *តុលាការព្រហ្មទណ្ឌអន្តរជាតិ Archbol* (២០០៥), ទំព័រ ១៦៥ ។ ជាឧទាហរណ៍ គោលការណ៍នេះត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង *Akayesu,* សាលក្រម ចុះថ្ងៃទី២ វិច្ឆិកា ១៩៩៨ កថាខណ្ឌ ៣១៩ ដែលអង្គជំនុំជម្រះសាលាដំបូង ICTR សម្រេចថា "ដោយសារតែគោលការណ៍ច្បាប់ទូទៅចែងថា នៅក្នុងបញ្ហាព្រហ្មទណ្ឌ ការបកស្រាយដែលជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវតែយកមកប្រើប្រាស់" ។

41. ដូច្នេះ ឧក្រិដ្ឋកម្មបាត់ខ្លួនដោយបង្ខំ មិនអាចបញ្ចូលទៅក្នុងប្រភេទសេសសល់នៃអំពើអមនុស្សធម៌ផ្សេងទៀតបានទេ។

**VI. ទឡ្ហីករណ៍ IV-ស្ថានភាពនៃបទល្មើស គឺមិនពាក់ព័ន្ធនោះទេ**

42. បន្ទាប់មក សំណើសុំនោះជំទាស់តវ៉ាយ៉ាងទូលំទូលាយថា បទល្មើសបាត់ខ្លួនដោយបង្ខំបានឈានដល់បទដ្ឋានដែលត្រូវអនុវត្ត *(jus cogens)* ដែលនាំឱ្យមានការស៊ើបសួរបទល្មើសទាំងនេះ និងផ្តន្ទាទោសនៅចំពោះមុខ អវតក ។

43. មេធាវីការពារសូមសន្និដ្ឋានថា ការកំណត់ឈ្មោះបទល្មើសនេះ គឺមិនទាក់ទងនោះទេ។ ដូចដែលបានជជែកតវ៉ាខាងលើ បទល្មើសនេះស្ថិតនៅក្រៅយុត្តាធិការរបស់ អវតក។ ហេតុដូច្នេះ វាមិនអាចយកមកចោទប្រកាន់បានទេ។ បទល្មើសនេះមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ នៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់តុលាការនេះ តែវាជាផ្នែកមួយនៃបទដ្ឋានតែត្រូវតែអនុវត្ត *(jus cogens)* ប៉ុណ្ណោះ[35]។

**VII. សេចក្តីសន្និដ្ឋាន**

44. ដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិអំណាចស្នើសុំឱ្យមានការបន្ថែមបទល្មើសមួយថ្មី ទៅលើបទល្មើស ដែលជនត្រូវចោទកំពុងរងការចោទប្រកាន់នោះទេ។ ក្រៅពីដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិអំណាចធ្វើបែបនេះបាននោះ អវតក ក៏មិនមានយុត្តាធិការជំនុំជម្រះលើជនត្រូវចោទចំពោះបទល្មើសបាត់ខ្លួនមនុស្សដោយបង្ខំបានដែរ។ បទល្មើសនេះមិនស្ថិតនៅក្រោមច្បាប់បង្កើត អវតក ដែលកំណត់ព្រំដែនយុត្តាធិការរបស់ អវតក នោះទេ ហើយវាក៏មិនបានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នៅពេលវេលាពាក់ព័ន្ធនោះដែរ។ បទល្មើសនេះសោតទៀតមិនបានបង្កើតជាផ្នែកមួយនៃច្បាប់អន្តរជាតិ ហើយ ជាចុងក្រោយបទល្មើសបាត់ខ្លួនដោយបង្ខំ មិនត្រូវបានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិមួយ ដែលមានការអនុវត្តដោយផ្ទាល់នៅចំពោះមុខ អវតក ។

---

[35] សំណើសុំនោះក៏មិនបានជំទាស់ថា បទល្មើសនេះជាផ្នែកមួយនៃបទដ្ឋានដាច់ខាត *(jus cogens)* នៅចន្លោះពីឆ្នាំ ១៩៧៥ - ១៩៧៩ នោះទេ ហើយសំណើនេះមិនបានបញ្ជាក់អំឡុងពេលវេលាឱ្យបានច្បាស់លាស់នោះដែរ។ សូមមើលសំណើសុំកថាខណ្ឌទី ៦។

45. សម្រាប់ហេតុផលទាំងអស់នេះ អវតក មិនមានយុត្តាធិការផ្តន្ទាទោសជនត្រូវចោទទាំងអស់ទៅលើបទល្មើសបាត់ខ្លួនដោយបង្ខំនោះទេ។ ការធ្វើបែបនេះអាចរំលោភទៅលើគោលការណ៍ច្បាប់អន្តរជាតិដែលកំណត់ថា គ្មានបទល្មើសទេ បើគ្មានច្បាប់ចែង ។ ការប៉ុនប៉ងកែប្រែអង្គហេតុទាំងនេះឡើងវិញ អាចនាំឱ្យមានការរំលោភគោលការណ៍នេះ។

46. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានលើកឡើងថា បទល្មើសបាត់ខ្លួនមនុស្សដោយបង្ខំស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក នោះទេ។ ជាលទ្ធផល សំណើសុំឱ្យ"បំពេញកិច្ចស៊ើបសួរមួយឱ្យបានពេញលេញពាក់ព័ន្ធទៅនឹងអត្ថិភាពនៃបទល្មើសបាត់ខ្លួនដោយបង្ខំនោះ"[36] ត្រូវតែបដិសេធចោល។

## VII. សំណូមពរ

47. ចំពោះហេតុផលខាងលើ មេធាវីការពារក្តីសូមស្នើឱ្យបដិសេធសំណើសុំនោះទាំងស្រុងតែម្តង។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| **សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ** | | | |
| ២៤ កក្កដា ២00៩ | លោក ផាត់ ពៅស៊ាង<br>កញ្ញា Diana ELLIS, QC | រាជធានីភ្នំពេញ | |
| **សហមេធាវីរបស់លោក នួន ជា** | | | |
| ២៤ កក្កដា ២00៩ | លោក សុន អរុណ<br>លោក Victor KOPPE<br>លោក Michiel PESTMAN | រាជធានីភ្នំពេញ | |

[36] សំណើសុំ កថាខណ្ឌទី ២៧។